# Decision
# N.30 SSR
## The appointment of an Economic Advisor to the Prime Minister of the Kingdom of Cambodia

000

**The Royal Government**

- Having seen the constiution of the Kingdom of Cambodia
-Having seen the RoyalDecree N NS.RKT.1198.72 dated November 30 th 1998 on the appointment of the Royal Govrnmemt of the Kingdom of Cambodia
-Having seen the Reachkrom N 02.NS.94 dated july 20 th 1994 which promulgated the law on the organization and functioning of the Council of Ministers
-Pursuant to the needs of the Royal Govrnment of Cambodta

**Hereby Decides :**

**Article 1 :** To appoiut Tan Sri Dr.Chen Lip Keong as an Economic Advisor to samdech Hun sen, prime Minister of the Royal Government of Cambodia

**Article 2 :** Tan sri Dr Chen Lip Keong has to implement this decision from the date of its signature .

Phnom Penh june 5 th 2001

HUN SEN
Prime Minister

===

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

**សេចក្ដីសំរេចលេខ ៣១ សសរ**

**ស្ដីពីការបង្កើតគណៈកម្មការការពារសវនាការតុលាការវិនិច្ឆ័យ**
**ករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម ឈុន យ៉ាសិទ្ធិ**

---

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-លិខិតលេខ ៩៣៣ រប-២០០១ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១ របស់ក្រសួងយុត្តិធម៌

-ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០១

-យោងតាមការចាំបាច់

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតគណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យករណីភេរវកម្មប្រដាប់អាវុធដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **សូរ ផន** អគ្គនាយករងទី១នគរបាលជាតិ ជាប្រធាន

២-ឯកឧត្តម **ថ្រាក់ ស៊ីមហាវ៉ា** អគ្គនាយករងទី១ អគ្គរដ្ឋបាល ជាអនុប្រធាន

៣-លោកឧត្តមសេនីយ៍ទោ **នេត សាវឿន** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ អនុប្រធានអចិន្ត្រៃយ៍

៤-លោកឧត្តមសេនីយ៍ត្រី **ខេង ពិសេន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ អនុប្រធាន

៥-លោកឧត្តមសេនីយ៍ត្រី **ប៉ូ លីជា** អនុប្រធានទី១នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ សមាជិក

៦-លោកឧត្តមសេនីយ៍ត្រី **សុខ ផល** ប្រធាននាយកដ្ឋានពត៌មានទូទៅ សមាជិក

៧-លោកឧត្តមសេនីយ៍ត្រី **គន្ធ សំអឿន** ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម សមាជិក

៨-លោកឧត្តមសេនីយ៍ត្រី **សួន ឈាងលី** ស្នងការនគរបាលក្រុងភ្នំពេញ សមាជិក

៩-លោកឧត្តមសេនីយ៍ត្រី **ឡៅ ស៊ុនឆៃ** ប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ សមាជិក

១០-លោកឧត្តមសេនីយ៍ត្រី **ហុក ធីន** ប្រធាននាយកដ្ឋានតម្រួតការពារ សមាជិក

១១-លោក **ស្រេង ស្រ៉ាង** ប្រធានស្តីទីនាយកដ្ឋានពន្ធនាគារ សមាជិក

១២-លោក **ឈឹម នី** អនុប្រធានទី១នាយកដ្ឋានពន្ធនាគារ សមាជិក

www.pheakdeylaw.com

**ប្រការ ២** : គណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** មានភារកិច្ច :

-រៀបចំគំរោងផែនការការពារសុវត្ថិភាពដល់ដំណើរការនៃអង្គសវនាការទាំងស្រុង

-ការពារសុវត្ថិភាព ការដឹកជញ្ជូនទៅ មកពិរុទ្ធជនពីចំណុច ម១ មកកាន់ទីកន្លែងសវនាការ

-ការពារកន្លែងឃុំខ្លួនពិរុទ្ធជនជាបណ្តោះអាសន្ន រងចាំការបើកសវនាការ

-ការពារសុវត្ថិភាពកន្លែងបើកសវនាការ

-ទប់ស្កាត់និងបង្ក្រាបអោយបានទាន់ពេលវេលារាល់ការប៉ុនប៉ងវាយរំដោះពិរុទ្ធជន ក្នុងគ្រប់ករណី និងគ្រប់កាលៈទេសៈ

-ទប់ស្កាត់ និងបង្ក្រាបអោយបានទាន់ពេលវេលារាល់ការប៉ុនប៉ងផ្សេងៗ ដែលសំដៅបង្កការវិខាន ឬ ធ្វើអោយរាំងស្ទះដល់ការបើកសវនាការ

-រៀបចំសណ្តាប់ធ្នាប់បរិវេណខាងក្រៅអង្គពិធីសវនាការ

-ពង្រឹងការងារក្តាប់សភាពការណ៍ ដែលពាក់ព័ន្ធដល់ដំណើរការសវនាការ

-អនុវត្តភារកិច្ចការពារផ្សេងៗទៀតដែលមានការពាក់ព័ន្ធ

**ប្រការ ៣** : គណៈបញ្ជាការការពារសវនាការតុលាការវិនិច្ឆ័យករណីភេរវកម្មប្រដាប់អាវុធ ដែលបានប្រព្រឹត្តដោយក្រុម **ឈុន យ៉ាសិទ្ធិ** ត្រូវមានកិច្ចសហប្រតិបត្តិការអោយបានជិតស្និទ្ធ ជាមួយអាជ្ញាធរ មានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្តភារកិច្ចការពារអោយទទួលបានជោគជ័យ ។ គណៈបញ្ជាការការពារត្រូវកសាងផែនការឯកភាពមួយរវាងអគ្គនាយកដ្ឋាននគរបាលជាតិ ស្នងការដ្ឋាននគរបាលក្រុងភ្នំពេញ និងកងរាជអាវុធហត្ថក្រុងភ្នំពេញ ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គនាយក នៃអគ្គនាយកដ្ឋាននគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

**ស ខេង**

www.pheakdeylaw.com